**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ
លេខ ០៣៦ សជណ/គ.ជ.វ.វ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៧

# សេចក្តីសម្រេច
## ស្តីពី
## ការបន្ថែមតួនាទីក្រុមការងារ គ.ជ.វ.វ
## ជាក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ

## គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៩៥ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈ កម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមការងាររបស់គណៈកម្មា ធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងស្មារតីអង្គប្រជុំលើកទី៣ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧ ។

## សម្រេច

**ប្រការ ១.-**

ត្រូវបានបន្ថែមតួនាទីក្រុមការងាររបស់ គ.ជ.វ.វ ជាក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការសប្រមសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់បម្រើឱ្យវេទិកា សហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា។

**ប្រការ ២.-**

លេខាធិការដ្ឋានរបស់ គ.ជ.វ.វ ត្រូវបំពេញតួនាទីបន្ថែមជាលេខាធិការដ្ឋានរបស់ក្រុមការងារបច្ចេក-ទេស ស្តីពីវិមជ្ឈការ និង វិសហមជ្ឈការ ។

**ប្រការ ៣.-**

ក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវរៀបចំលក្ខខណ្ឌការងារ និងរបៀបរបបធ្វើការងាររបស់ខ្លួន ស្របតាមលក្ខខណ្ឌនានារបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាកិច្ចសម្របសម្រួល និងពិគ្រោះយោបល់ក្នុងកម្រិតបច្ចេកទេស ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យវិមជ្ឈការ និងវិសហមជ្ឈការ រវាងស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងសហគមន៍ដៃគូអភិវឌ្ឍន៍ ។

**ប្រការ ៤.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ជ.គណៈកម្មាធិការជាតិដឹកនាំការងារ**
**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**
**ប្រធាន**

ស ខេង

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- សមាជិក គ.ជ.វ.វ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
  (ដើម្បីជូនជ្រាប)
- សមាជិកក្រុមការងារ គ.ជ.វ.វ
- លេខាធិការដ្ឋាន គ.ជ.វ.វ
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ : ៩៣៦៩ ស.ស

**សូមគោរពជូន**

## សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**កម្មវត្ថុ** : សំណើសូមប្រគល់ឱ្យក្រុមការងាររបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ "គ.ជ.វ.វ" ឱ្យទទួលភារកិច្ចបន្ថែមជាក្រុមការងារបច្ចេកទេសវិមជ្ឈការ និង វិសហមជ្ឈការ ។

**យោង** : អនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមការងាររបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជំរាប សម្តេចនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា នៅក្នុងយន្តការនៃគណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ សំរាប់បំរើឱ្យវេទិកានៃកិច្ចប្រជុំពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលទើបនឹងបានប្តូរមកជាវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា បានបង្កើតឡើងនូវក្រុមការងារបច្ចេកទេស(TWG)នានាជាច្រើន ក្នុងនោះក៏មានក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និង វិសហមជ្ឈការផងដែរ ។

ទន្ទឹមនេះ នៅក្នុងយន្តការគណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការក៏បានបង្កើតឱ្យមានក្រុមការងារមួយដែលមានភារកិច្ចធ្វើការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មាន និង ការសំរបសំរួលដល់ការគាំទ្រពីដៃគូអភិវឌ្ឍន៍នានាក្នុងដំណើរការកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការផងដែរ ។

ដើម្បីសំរបសំរួលការងារនេះ ក្នុងកិច្ចប្រជុំ គ.ជ.វ.វ លើកទី៣ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧កន្លងទៅនេះ អង្គប្រជុំបានឯកភាពប្រគល់ឱ្យក្រុមការងាររបស់ គ.ជ.វ.វ ទទួលភារកិច្ចបន្ថែមជាក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីធានាឱ្យមានភាពរលូននៅក្នុងការសំរបសំរួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ អំពីកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ។

អាស្រ័យហេតុនេះ សូមសម្តេចនាយករដ្ឋមន្ត្រី មេត្តាពិនិត្យ សំរេច ដោយអនុគ្រោះ ។

សូមសម្តេច មេត្តាទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

23-7-2007

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

D&D